# ការយល់ឃើញរបស់ខ្ញុំ

ដោយ ណុប វ៉ាន់ដា
និសិត្សសាកលវិទ្យាល័យបញ្ញាសាស្ត្រ

បន្ទាប់ពីបានអានវគ្គទាំង៤ នៃការចាក់ផ្សាយរបស់វិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាចាប់ពីវគ្គទី៤ ដល់ វគ្គទី៧ ធ្វើឱ្យខ្ញុំទទួលបានចំណេះដឹងជាច្រើនទាក់ទងទៅនឹង ការអត់ឃ្លាន ដែលបណ្តាលមកពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការអត់ឃ្លាននៅសម័យបច្ចុប្បន្ន។

ចំពោះវគ្គទី៤ ដែលនិយាយអំពីការអត់ឃ្លាន និងអំពើប្រល័យពូជសាសន៍ ដែលបានក្លាយជាចំណីមួយយ៉ាងថ្មីសំរាប់ការជាចំណេះដឹង ដែលខ្ញុំមិនធ្លាប់បានដឹងពីមុនមកថា អំពើប្រល័យពូជសាសន៍ជាការសម្លាប់ដោយចេតនាទៅលើក្រុមមនុស្ស ឬពូជសាសន៍ណាមួយ។ លើសពីនេះទៅទៀតឧក្រិដ្ឋកម្មនេះកើតឡើងតាំងពី ការប៉ុនប៉ងរបស់បក្សណាហ្ស៊ី-អាឡឺម៉ង់ ដើម្បីកំចាត់ជនជាតិជ្វីបចេញពីអឺរ៉ុបម្លេះ។ បទឧក្រិដ្ឋកម្មដែលអាចចាត់ទុកថាអំពើប្រល័យពូជសាសន៍ លុះត្រាតែចូលក្នុងធាតុផ្សំទាំងបីខាងក្រោមៈ

១. ការប្រព្រឹត្តិសកម្មភាពមួយក្នុងសកម្មភាពទាំង៥រួមមាន ១ ការសម្លាប់សមាជិកក្នុងក្រុម ២ ការបង្កឱ្យឈឺខូចខាតដំណាំ និង ប៉ះពាល់ដល់ស្មារតីនៅក្នុងក្រុម ៣ បង្កឱ្យមានគ្រោះមហន្តរាយដោយចេតនា ៤ មិនឱ្យមានការបង្កកំណើត និង ៥ ការពង្រាតកូនចេញពីម្តាយឪពុក។

២. សកម្មភាពខាងលើត្រូវផ្តោតទៅលើក្រុម ដូចជាក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ និង សាសនា។

៣. ជនដែលប្រព្រឹត្តសកម្មភាព ខាងលើដោយបំណងជាក់លាក់ ដើម្បីកម្ទេចក្រុមណាមួយដែលបានរៀបរាប់ខាងលើ។

ទោះបីជាយ៉ាងណាក៏ដោយ ការបង្អត់អាហារចាត់ទុកថាជាអំពើប្រល័យពូជសាសន៍។ ទង្វើនេះត្រូវបានប្រព្រឹត្តឡើងដោយការប៉ុនប៉ង ដើម្បីបង្អត់អាហារឱ្យដាច់ពោះស្លាប់តែម្តង។ តួយ៉ាងនៅក្នុងរបបខ្មែរក្រហមបានចាត់ចូលក្នុងអំពើប្រល័យពូជសាសន៍ដែរដោយសារមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ បានធ្វើទុក្ខបុកម្នេញមកលើជនជាតិឯង ដោយការបង្ខំឱ្យធ្វើការហួសកម្លាំង ការសម្លាប់ដោយគ្មានកំហុស ការគម្រាមកំហែងបំបាក់ស្មារតី ការពង្រាត់ពង្រាស់កូនចៅ ប្តីប្រពន្ធ និង ជាពិសេសគឺការបង្អត់អាហារ។ ហើយអ្វីដែលថ្មីចំពោះខ្ញុំនោះ គឺកាលពីមុនខ្ញុំគិតថាឱ្យតែខ្មែរក្រហមសុទ្ធតែអាក្រក់ទាំងអស់ ប៉ុន្តែដោយយោងទៅតាមការចាក់ផ្សាយវគ្គទី៤ បានលើកឡើងថាខ្មែរក្រហមមិនអាក្រក់ទាំងអស់នោះទេ ដូចជាអត្ថបទមួយដែលមានចំណងជើងថា "តើខ្មែរក្រហមទាំង

អស់សុទ្ធតែអាក្រក់ឬ?" ដែលចេញផ្សាយដោយទស្សនាវដ្ដីស្វែងរកការពិត លេខ១០៤ ខែសីហា ឆ្នាំ២០០៨ សរសេរដោយ សោម ប៊ុនថន។

ចំពោះវគ្គទី៥ និយាយអំពីការអត់ឃ្លាន និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយក្នុងវគ្គនេះដែរខ្ញុំបានយល់ច្បាស់ថាអ្វីជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ មានន័យថាជាសេចក្ដីប្រកាស់ដែលចេញរួមគ្នារវាងបារាំង អង់គ្លេស និងសូវៀត ដើម្បីចោទប្រកាន់ជាតិសាសន៍អាមានាពីបទសម្លាប់រង្គាល់នៅក្នុងចក្រភពទួរគីអូតូម៉ែន។ ហើយអំពើនេះត្រូវបានកាត់ទោសដោយតុលាការជាច្រើនដូចជា តុលាការប្រទេសយូហ្គោស្លាវី រ៉្វាន់ដា សេរ៉ាលេអូន និង តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ក៏ដូចជាតុលាការកាត់ទោសមេដឹងនាំខ្មែរក្រហម។ ទង្វើដែលចាត់ទុកថាជាអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិកាលណាឧក្រិដ្ឋកម្មនោះឆ្លុះបញ្ចាំងនូវការវាយប្រហារជាទូទៅ សំដៅទៅលើការវាយប្រហារដែលកើតឡើងពេញផ្ទៃប្រទេស ឬកើតក្នុងរយៈពេលយូរ និង ការវាយប្រហារជា ប្រព័ន្ធដែលការវាយប្រហារដោយចំពោះ ដោយមិនបានគ្រោងទុក និង ការរៀបចំទុកជាមុន។ លើសពីនេះទៅ ទៀត ការអត់ឃ្លាន និង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺមានការពាក់ព័ន្ធទៅនឹងការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ និង អំពើអមនុស្សធម៌ផ្សេងៗ។

ចំពោះវគ្គទី៦ កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការបកស្រាយអំពី ភាពអត់ឃ្លាន និង ឧក្រិដ្ឋកម្មសង្គ្រាម។ ឆ្លងកាត់វគ្គនេះដែរខ្ញុំបានយល់កាន់តែច្បាស់អំពី អំពើឧក្រិដ្ឋកម្មមួយទៀតគឺឧក្រិដ្ឋកម្មសង្គ្រាម បានដល់ការរំលោភបំពាន់ធ្ងន់ធ្ងរទៅលើច្បាប់សង្គ្រាម ដែលមានឈ្មោះជាផ្លូវការថា "ច្បាប់មនុស្សធម៌អន្តរជាតិ"។ លើសពីនេះទៅទៀតច្បាប់សង្គ្រាម សំដៅទៅលើទង្វើទាំងឡាយណាដែលប្រព្រឹត្តិឡើងក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធ ហើយទង្វើទាំងនោះបានរំលោភបំពានទៅលើច្បាប់ដែលពាក់ព័ន្ធទៅនឹងការការពារជនទាំងឡាយដែលមិនបានចូលរួមក្នុងការធ្វើសង្គ្រាមដូចជាប្រជាជនស៊ីវិល ទាហ៊ាន ដែលរងរបួស និង ជនឈ្លើយសឹក ព្រមទាំងក្រុមដែលទទួលបានការការពារ។ ចំពោះឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងតុលាការកាត់ទោសមេដឹងនាំខ្មែរក្រហមវិញ ដែកឧក្រិដ្ឋកម្មនេះត្រូវបានបង្កឡើងដោយការបង្អត់អាហារប្រជាជនដោយចេតនា ជាមធ្យោបាយក្នុងការធ្វើសង្គ្រាម។ ចំពោះឧក្រិដ្ឋកម្មមួយចំនួនផ្សេងទៀតហាក់បីដូចជាមានការពាក់ព័ន្ធនឹងការអត់ឃ្លាន ដែលបានកើតឡើងក្នុងរបបខ្មែរក្រហមដូចជា ការសម្លាប់ដោយចេតនា ការធ្វើទារុនកម្ម ឬការធ្វើទុក្ខបុកម្នេញ ការបង្កឱ្យមានការឈឺចាប់ ឬរបួសធ្ងន់ធ្ងរទៅលើផ្លូវការ ឬសុខភាពដោយចេតនា និង ការនិរទេស ឬផ្លាស់ប្ដូរកន្លែងរស់នៅ ឬការឃុំឃាំងប្រជាជនស៊ីវិលដោយខុសច្បាប់។

ជាចុងក្រោយ វគ្គទី៧ នៃវិទ្យុសហគមន៍បាននិយាយអំពីយុត្តិធម៌ និងភាពអត់ឃ្លាននៅសម័យបច្ចុប្បន្ន។ នៅក្នុងវគ្គនេះផ្ដោតសំខាន់ទៅលើការអត់ឃ្លាន ដែលអ្នកប្រាជ្ញបានឱ្យនិយមន័យថា វាកើតឡើងដោយសារ

គ្រោះធម្មជាតិ ឬកត្តាផ្សេងៗ ដែលប៉ះពាល់ទៅដល់បរិមាណស្បៀងអាហារផលិតនៅនៅក្នុងប្រទេស ឬតំបន់ដែលរងគ្រោះដោយសារគ្រោះទុរភិក្ស។ និយាយលេងអីការអត់ឃ្លានគឺជាជំងឺមួយយ៉ាងសាហាវ ដែលបានសម្លាប់មនុស្សរាប់លាននាក់ ថ្វីបើមានការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗសម្រាប់ធ្វើកសិកម្មយ៉ាងណាក៏ដោយ ក៏វានៅតែកើតឡើងដែរ។ ជាក់ស្តែងនៅសតវត្សរ៍ទី២០ មានជនរងគ្រោះប្រមាណជាង៧០លាននាក់បានស្លាប់ដោយសារ ការអត់ឃ្លាន។ តួយ៉ាងនៅក្នុងសម័យប៉ុល ពត ភាពអត់ឃ្លានបានកើតឡើងទៅលើប្រជាជនទាំងអស់នូវក្នុងប្រទេសទាំងមូលក្នុងរយៈពេលជិត៤ឆ្នាំ។ ចង់ជំរាប់ថាភាពអត់ឃ្លានទាំងនោះមិនមែនកើតឡើងដោយសារអាកាសធាតុ ឬគ្រោះទុរភិក្សអីនោះទេ ប៉ុន្តែវាកើតឡើងដោយសារការបង្អត់អាហារពីសំណាក់មេដឹកនាំជាន់ខ្ពស់ទៅវិញ។ តាមអ្វីដែលខ្ញុំបានដឹងនៅក្នុងសម័យខ្មែរក្រហម និយាយអំពីការបង្កបង្កើនផល ជាពិសេសដំណាំស្រូវគឺទទួលបានទិន្នផលយ៉ាងច្រើនក្នុងមួយឆ្នាំៗដោយមិនមានហានិភ័យអ្វីមកយាយីសោះឡើយ។ ផ្ទុយមកវិញផលិតផលស្រូវទាំងអស់ហ្នឹងមិនត្រូវបានយកមកផ្គត់ផ្គង់ការហូបចុករបស់ប្រជាជនទេ ធ្វើឱ្យប្រជាជនទទួលរងនូវការអត់ឃ្លានយ៉ាងខ្លាំង ហើយធ្វើការធ្ងន់ៗបណ្តាលឱ្យប្រជាជនបាក់កំលាំងស្លាប់អស់យ៉ាងច្រើននាក់។ តាមការសិក្សាស្រាវជ្រាវរបស់ខ្ញុំៗបានដឹងថាផលស្រូវដែលប្រមូលបាន មួយចំនួនធំត្រូវយកទៅធ្វើពាណិជ្ជកម្មជាមួយនឹងប្រទេសក្រៅដើម្បីដូរយកលុយដើម្បីទិញអាវុធ ទុកធ្វើសង្គ្រាមជាមួយវៀតណាម មួយចំនួនទៀតយកទៅផ្គត់ផ្គង់កងទ័ពនៅសមរភូមិ មួយចំនួនទៀតទុកធ្វើពូជ និងមួយចំនួនតូចទុកឱ្យប្រជាជនបរិភោគ។ ដូច្នេះហើយទើបឱ្យប្រជាជនហូបតែបបរលាយជាមួយនឹង ត្រកួន និង ព្រលិតអញ្ចឹងឯង។

សរុបសេចក្តីមក ចំពោះកម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើឱ្យប្រិយមិត្តអ្នកស្តាប់ទទួលបានចំណេះដឹងជាច្រើនជុំវិញបញ្ហាច្បាប់ ការកាត់ទោសមេដឹកនាំជាន់ខ្ពស់ក្នុងរបបខ្មែរក្រហម ការធ្វើឱ្យមានអំពើប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មនានា និង ជាពិសេសរឿងរ៉ាវពិតៗនៅក្នុងសម័យខ្មែរក្រហមតែម្តង។ តាមរយៈការអានវគ្គទាំង៤នេះហាក់បីដូចជាទទួលចំណេះដឹងច្រើនដែលខ្ញុំពុំធ្លាប់បានដឹងពីមុនមកដូចជាអត្ថបទនៃបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងភាពអត់ឃ្លាននានា។ តាមរយៈកម្មវិធីនេះដែរ ខ្ញុំយល់ឃើញថារាល់ពាក្យពេជ្យ ឃ្លាឃ្លោង វេយ្យាករណ៍ និង អត្ថបទរឿងរ៉ាវទាក់ទងនឹងខ្មែរក្រហមគឺមានភាពពិត ច្បាស់លាស់ និង ងាយស្រួលយល់។ ជាចុងក្រោយខ្ញុំសូមឱ្យមានការចាក់ផ្សាយនូវកម្មវិធីវិទ្យុសហគមន៍នេះឱ្យបានច្រើនបន្តិច ដើម្បីឱ្យវាបានជ្រោតជ្រាបទៅដល់គ្រប់តំបន់ទាំងអស់ក្នុងប្រទេសកម្ពុជាបានដឹងគ្រប់ៗគ្នា។ ជាប្រយោជន៍វាអាចជួយឱ្យអ្នកជំនាន់ក្រោយដឹងអំពីប្រវត្តិសាស្ត្រខ្លួនឯងឱ្យបានច្បាស់ ព្រមទាំងអាចបញ្ចៀសពួកគេមិនឱ្យប្រព្រឹត្តអំពើដ៏លល្ងង់ខ្លៅនេះតទៅទៀត។